# មាតាបង្រៀនកូនៗនៅក្នុងគេហដ្ឋាន

*អែលឌើរ អិល ថម ភែរី*
*នៃកូរ៉ុមពួកសាវកដប់ពីរនាក់*

ក្នុងពេលថ្មីៗនេះ ខ្ញុំមានឱកាសដើម្បីធ្វើដំណើរជាមួយនឹងអែលឌើរ ហាល់ស្ទូម ដើម្បីទៅទស្សនាទីក្រុងចំនួនប្រាំ នៅតំបន់ភាគកណ្តាលសហរដ្ឋដ៏ធំ។ នៅក្នុងទីក្រុងនីមួយៗ ដែលយើងទៅទស្សនា យើងមានការប្រជុំមួយជាមួយនឹង ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ព្រមទាំងមានការប្រជុំជាមួយនឹងពួកអ្នកដឹកនាំក្នុងស្តេក និងវួដស្តីអំពីកិច្ចការផ្សព្វផ្សាយសាសនាផងដែរ។ រវាងការប្រជុំនីមួយៗនៃការប្រជុំទាំងពីរនេះ សមាគមសង្គ្រោះស្តេក នឹងរៀបចំអាហារសំរន់ខ្លះៗសម្រាប់ពួកយើង ដើម្បីផ្តល់ពេលឱ្យពួកយើង ជួបជាមួយនឹងប្រធានស្តេក។ នៅពេលយើងទៅដល់ មិលវ៉ាគី និងវីសខូនសីន គ្រួសារវ័យក្មេងពីរគ្រួសារ បានសុំទៅកាន់សមាគមសង្គ្រោះ ដើម្បីទុកឱ្យពួកគេរៀបចំ និងបំរើអាហារពេលល្ងាច។ ស្វាមីពីររូបធ្វើការនៅក្នុងចង្ក្រានបាយ។ ម្តាយពីររូបគ្រប់គ្រងលើការរៀបចំតុអាហារ និងបំរើអាហារ។ កូនក្មេងបីនាក់ កាន់ខាងការរៀបចំតុ និងការបំរើអាហារ នៅក្រោមការគ្រប់គ្រងរបស់ម្តាយ។ នេះគឺជាឱកាសមួយសម្រាប់ម្តាយ មានឱកាសបង្រៀនដល់កូនៗរបស់ពួកគេ។ វាគឺជារឿងដ៏ពិសេស ដើម្បីមើលឃើញកុមារតូចៗ ឆ្លើយតបទៅនឹងការលំអិតៗ ដូចដែលពួកគេត្រូវបានបង្រៀនដោយម្តាយរបស់ពួកគេ។ ពួកគេមានភាពល្អឥតខ្ចោះនៅក្នុងការអនុវត្តន៍កិច្ចការរបស់ពួកគេយ៉ាងលំអិត។

តាមបទពិសោធន៍នេះ បានបណ្តាលឱ្យខ្ញុំ ឆ្លុះបញ្ចាំងអំពីការបំពាក់បំប៉ន ដែលខ្ញុំមានមកពីម្តាយរបស់ខ្ញុំ។ ដូចជាព្យាការីនីហ្វៃ និងដូចជាអ្នករាល់គ្នាភាគច្រើន ខ្ញុំបានកើតមកពីឪពុកម្តាយល្អ។

ក្មួយម្នាក់របស់ខ្ញុំ ក្នុងពេលថ្មីៗនេះ បានចែកចាយជាមួយនឹងខ្ញុំនូវសៀវភៅកំណត់ហេតុចំនួនបួនក្បាលរបស់ម្តាយខ្ញុំ ដែលមានពេញទៅដោយការកំណត់ចំណាំ ដែលគាត់បានរៀបចំ ដើម្បីបង្រៀនថ្នាក់របស់គាត់ ក្នុងសមាគមសង្គ្រោះ។ ខ្ញុំនឹកស្រមៃអំពីសៀវភៅកំណត់ហេតុទាំងនេះ--- ហើយមានសៀវភៅផ្សេងទៀត ដែលខ្ញុំមិនទាន់បានមើលនៅឡើយ--- ដែលតំណាងឱ្យការរៀបចំរាប់រយម៉ោងដោយម្តាយរបស់ខ្ញុំ។

ម្តាយរបស់ខ្ញុំ គឺជាគ្រូបង្រៀនដ៏អស្ចារ្យម្នាក់ ដែលឧស្សាហ៍ព្យាយាម និងហ្មត់ចត់នៅក្នុងការរៀបចំរបស់គាត់។ ខ្ញុំបានចងចាំយ៉ាងច្បាស់ អំពីថ្ងៃទាំងឡាយ ពីមុនមេរៀនរបស់គាត់។ នៅលើតុអាហារនឹងមានពេញទៅដោយឯកសារយោង និងកំណត់ចំណាំ ដែលគាត់ត្រូវរៀបចំមេរៀនរបស់គាត់។ មានឯកសារដែលបានរៀបចំជាច្រើន ដែលខ្ញុំគិតថាមានតែមួយចំណែកតូចប៉ុណ្ណោះ ដែលត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀន ប៉ុន្តែខ្ញុំក៏ដឹងប្រាកដផងដែរថា គ្មានការរៀបចំណាមួយរបស់គាត់ឥតប្រយោជន៍នោះឡើយ។ តើខ្ញុំអាចដឹងប្រាកដអំពីរឿងនេះបានដោយរបៀបណា? នៅពេលខ្ញុំមើលក្នុងសៀវភៅកំណត់ហេតុរបស់គាត់ ដូចជាខ្ញុំកំពុងតែស្តាប់គាត់ បង្រៀនមកខ្ញុំម្តងទៀតដូច្នោះដែរ។ ជាថ្មីម្តងទៀត មានប្រធានបទច្រើនណាស់នៅ

ក្នុងសៀវភៅកំណត់ហេតុគាត់ ដែលត្រូវចែកចាយនៅក្នុងថ្នាក់រៀនមួយនោះ ប៉ុន្តែអ្វីដែលគាត់មិនបានប្រើប្រាស់នៅក្នុងថ្នាក់រៀន នោះគាត់ប្រើ ដើម្បីបង្រៀនដល់កូនៗរបស់គាត់វិញ។

ខ្ញុំជឿថា វាមិនអីទេ ក្នុងការនិយាយថា ខណៈដែលម្តាយរបស់ខ្ញុំ គឺជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាពយ៉ាងអស្ចារ្យ នៅក្នុងចំណោមបងប្អូនសមាគមសង្គ្រោះ ការបង្រៀនដ៏ល្អបំផុតរបស់គាត់ បានកើតមានឡើងជាមួយកូនៗរបស់គាត់ នៅក្នុងគេហដ្ឋាន។ ប្រាកដណាស់ នេះគឺព្រោះតែពេលវេលាដ៏ច្រើន ដែលគាត់ចំណាយ ដើម្បីបង្រៀនដល់កូនចៅរបស់គាត់ បើប្រៀបធៀបទៅនឹងការបង្រៀនដល់បងប្អូនស្ត្រីសមាគមសង្គ្រោះ ប៉ុន្តែខ្ញុំចូលចិត្តគិតផងដែរថា  គាត់បានរៀបចំយ៉ាងហ្មត់ចត់ ដំបូងគេ គាត់ត្រូវធ្វើជាគំរូដល់កូនៗរបស់គាត់ នៅក្នុងការបំរើសាសនាចក្រដោយឧស្សាហ៍ព្យាយាម  ហើយទីពីរ ដោយសារតែគាត់បានស្គាល់នូវអ្វីដែលគាត់បានរៀន មកពីការរៀបចំមេរៀនរបស់គាត់ ដែលអាចត្រូវបានប្រើប្រាស់ដដែលៗសម្រាប់គោលបំណងកាន់តែខ្ពស់--- ជាការបង្រៀនដល់កូនប្រុសស្រីរបស់គាត់។

សូមអនុញ្ញាតឱ្យខ្ញុំនិយាយមួយភ្លែត  ហើយចែកចាយមេរៀនខ្លះៗ ដែលខ្ញុំបានរៀនមកពីម្តាយរបស់ខ្ញុំ អំពីការបង្រៀនដំណឹងល្អនៅក្នុងគេហដ្ឋាន។ ម្តាយរបស់ខ្ញុំយល់អំពីតម្លៃនៃការបង្រៀនដល់កូនៗរបស់គាត់ អំពីបទដ្ឋាន គុណសម្បត្តិ និងគោលលទ្ធិទាំងឡាយ ខណៈដែលពួកគេនៅក្មេង។ ទោះបីជាគាត់មានអំណរគុណចំពោះអ្នកដទៃ ដែលបានបង្រៀនដល់កូនៗរបស់គាត់នៅក្រៅផ្ទះ ទាំងនៅសាលារៀន ឬនៅព្រះវិហារក្តី ក៏គាត់ស្គាល់ថា ឪពុកម្តាយ ត្រូវបានផ្តល់សិទ្ធិឱ្យអប់រំដល់កូនៗ ហើយទីបំផុត ឪពុកម្តាយត្រូវតែប្រាកដថា កូនៗរបស់គាត់ ត្រូវបានបង្រៀននូវអ្វីដែលព្រះវរបិតាសួគ៌របស់គាត់ ឱ្យពួកគេរៀន។ បងប្អូនរបស់ខ្ញុំ និងខ្ញុំ ត្រូវបានទទួលចំណោទសួរ ដោយយកចិត្តទុកដាក់ណាស់ មកពីម្តាយរបស់ពួកយើង បន្ទាប់ពីពួកយើងត្រូវបានបង្រៀននៅឆ្ងាយពីផ្ទះ ដើម្បីប្រាកដថា មេរៀនត្រឹមត្រូវបានចូលទៅដល់ត្រចៀករបស់ពួកយើង ហើយរៀបចំគំនិតរបស់ពួកយើង។

នៅពេលខ្ញុំរត់មកផ្ទះពីសាលារៀនវិញ ខ្ញុំធ្លាប់គិតអំពីថ្ងៃខ្លះថា ខ្ញុំបានរៀនចប់ហើយនៅថ្ងៃនេះ ប៉ុន្តែការគិតនេះ ត្រូវបានបំផ្លាញចោលភ្លាម នៅពេលខ្ញុំបានឃើញម្តាយរបស់ខ្ញុំ ឈរនៅមាត់ទ្វាររង់ចាំខ្ញុំ។ នៅពេលពួកយើងនៅតូច ពួកយើងម្នាក់ៗមានតុមួយនៅបន្ទប់ចង្ក្រានបាយ ជាកន្លែងដែលពួកយើងបន្តរៀនមកពីគាត់  ខណៈពេលដែល គាត់ធ្វើកិច្ចការផ្ទះ និងរៀបចំអាហារពេលយប់។ គាត់គឺជាគ្រូបង្រៀនមកពីធម្មជាតិ ហើយជំរុញពួកយើងច្រើនជាង គ្រូបង្រៀនរបស់យើង នៅសាលារៀន និងព្រះវិហារទៅទៀត។

ទំហំនៃការបង្រៀនរបស់ម្តាយខ្ញុំ រួមមានទាំងមេរៀនខាងលោកិយ និងមេរៀនខាងវិញ្ញាណ។ គាត់ត្រូវប្រាកដថា គ្មាននរណាម្នាក់ក្នុងចំណោមពួកយើង មិនបានធ្វើការងារសាលានោះឡើយ ដែលជារឿយៗគាត់ដាក់ការងារបន្ថែមដល់ពួកយើង។ គាត់ក៏អនុវត្តមេរៀនសមាគមសង្គ្រោះរបស់គាត់ជាមួយនឹងពួកយើងផងដែរ។ ប្រាកដណាស់ថា យើងបានទទួល រឿងដ៏វែងអន្លាយនៅក្នុងសៀវភៅកំណត់ហេតុរបស់

គាត់ ដែលមិនមែនជារឿងសង្ខេបៗ ដើម្បីឱ្យត្រូវនឹងពេលវេលានៃថ្នាក់រៀនមួយនោះទេ។

ជាចំណែកនៃការរៀនសូត្រនៅផ្ទះរបស់យើង ក៏មានជាប់ទាក់ទងនឹងការទន្ទេញបទគម្ពីរ មាត្រានៃសេចក្តីជំនឿ និងពាក្យសំដីរបស់ពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈផងដែរ។ ម្តាយរបស់ខ្ញុំ គឺជាមនុស្សម្នាក់ ដែលជឿថា គំនិតនឹងចាប់ផ្តើមទន់ខ្សោយ បើសិនជាវាមិនត្រូវបានអនុវត្តជាប្រចាំនោះ។ គាត់បានបង្រៀនពួកយើង នៅពេលពួកយើងលាងចាន កូរបឺរ ហើយជួយអ្វីផ្សេងៗទៀត។ គាត់មិនជឿទៅលើការទុកឱ្យគំនិតខ្ជិលច្រអូស ចូលមកក្នុងគំនិតកូនៗរបស់គាត់ទេ ទោះជាពួកគេមានជាប់ទាក់ទងនឹងកិច្ចការខាងរាងកាយក្តី។

ខ្ញុំមិនមែនកំពុងតែប្រើប្រាស់ម្តាយរបស់ខ្ញុំ ធ្វើជាគំរូដ៏សំខាន់មួយ សម្រាប់ឪពុកម្តាយនៅក្នុងលោកិយសព្វថ្ងៃនេះទេ។ ពេលវេលាសព្វថ្ងៃនេះមានភាពខុសគ្នាឆ្ងាយណាស់ ប៉ុន្តែខណៈដែលពេលវេលាអាចមានការផ្លាស់ប្តូរ នោះការបង្រៀនរបស់ឪពុកម្តាយ ត្រូវតែមានតម្លៃកាន់តែខ្លាំងឡើង។ មានសកម្មភាពជាច្រើនដែលភ្ជាប់គុណតម្លៃ ពីជំនាន់មួយទៅជំនាន់មួយទៀត ប៉ុន្តែប្រហែលជាសកម្មភាពដ៏សំខាន់បំផុតទាំងនេះ គឺជាការបង្រៀនរបស់ឪពុកម្តាយដល់កូនៗ នៅក្នុងគេហដ្ឋានរបស់ពួកគេ។ នេះគឺជាការពិតដ៏ពិសេស នៅពេលយើងពិចារណាអំពីការបង្រៀនអំពីគុណតម្លៃ សីលធម៌ និងបទដ្ឋានក្រមសីលធម៌ និងសេចក្តីជំនឿ។

ការបង្រៀននៅក្នុងផ្ទះ គឺកំពុងតែមានសារៈសំខាន់ខ្លាំងឡើងនៅក្នុងពិភពលោកសព្វថ្ងៃនេះ ជាកន្លែងដែលឥទ្ធិពលនៃសត្រូវ ត្រូវបានផ្សព្វផ្សាយយ៉ាងខ្លាំង ហើយវាកំពុងតែវាយប្រហារ  ប៉ុនប៉ងដើម្បីស៊ីច្រោះ និងបំផ្លាញគ្រឹះនៃសង្គមរបស់យើង គឺជាក្រុមគ្រួសារ។ ឪពុកម្តាយ ត្រូវតែសម្រេចចិត្តដ៏មុតមាំថា ការបង្រៀននៅក្នុងគេហដ្ឋាន គឺជាការទទួលខុសត្រូវដ៏ពិសិដ្ឋ និងសំខាន់បំផុត។ ខណៈដែលស្ថានប័នដទៃទៀត ដូចជាសាសនាចក្រ និងសាលារៀន អាចជួយឪពុកម្តាយ ដើម្បី «ចូរបង្ហាត់កូនក្មេង ឱ្យប្រព្រឹត្តតាមផ្លូវដែល [គាត់ ឬ] គួរប្រព្រឹត្ត» (សុភាសិត 22:6) នៅទីបំផុត ការទទួលខុសត្រូវនេះ ធ្លាក់មកលើឪពុកម្តាយ។ ស្របទៅតាមផែនការនៃសុភមង្គលដ៏មហិមា ឪពុកម្តាយត្រូវបានប្រគល់សិទ្ធិឱ្យមើលថែ និងអភិវឌ្ឍដល់កូនចៅរបស់ព្រះវរបិតាសួគ៌។ ក្រុមគ្រួសាររបស់យើង មានចំណែកមួយដ៏សំខាន់នៅក្នុងកិច្ចការ និងសិរីល្អរបស់ទ្រង់--- «ដើម្បីនាំឱ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស» (ម៉ូសេ 1:39)។ នៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ ជាធម្មតា ឪពុកម្តាយត្រូវបានបម្រុងទុកឱ្យដើរតួនាទីដ៏សំខាន់ នៅក្នុងជីវិតរស់នៅរបស់កូនចៅពួកគេ។ ជាជោគវាសនាល្អ មានមនុស្សដទៃទៀតដែលជាប់ពាក់ព័ន្ធនៅក្នុងជីវិតរស់នៅរបស់ពួកគេ ដែលអាចជួយ នៅពេលដែលឪពុកម្តាយមិនអាចធ្វើបាន។ តែទោះជាយ៉ាងណាក៏ដោយ ឪពុកម្តាយត្រូវបានបញ្ជាដោយព្រះអម្ចាស់ឱ្យ ចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្តីពិត។

ឪពុកម្តាយត្រូវតែនាំពន្លឺ និងសេចក្តីពិតចូលទៅក្នុងគេហដ្ឋានរបស់ពួកគេ ដោយការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ រាត្រីជួបជុំក្រុមគ្រួសារ ការអានសៀវភៅឱ្យខ្លាំងៗ ការច្រៀង និងពេលបរិភោគអាហារ

ជាគ្រួសារ។ ពួកគេស្គាល់ឥទ្ធិពលសុចរិត មនសិការ ភាពខ្ជាប់ខ្ជួន និងការចិញ្ចឹមបីបាច់ជាប្រចាំ នៅក្នុងចំណោមកម្លាំងដ៏មានអំណាចបំផុត និងកម្លាំងគាំទ្រសម្រាប់សេចក្តីល្អនៅក្នុងពិភពលោក។ សុខភាពរបស់សង្គម សុភមង្គលរបស់ប្រជាជនក្នុងសង្គម កូនចៅរបស់ពួកគេ និងសេចក្តីសុខសាន្តរបស់ពួកគេទាំងអស់ រកបាននៅក្នុងឫសគល់ដូចគ្នា នៅក្នុងការបង្រៀនកូនចៅនៅក្នុងគេហដ្ឋាន។

អែលឌើរ យ៉ូសែប ហ្វិលឌីង ស៊្មីធ បានបង្រៀនថា៖ «វាគឺជាកាតព្វកិច្ចរបស់ឪពុកម្តាយ ដើម្បីបង្រៀនដល់កូនចៅរបស់ពួកគេនូវគោលការណ៍ នៃការសង្គ្រោះទាំងនេះ នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីពួកគេនឹងស្គាល់ថាហេតុអ្វីបានជាពួកគេត្រូវទទួលបុណ្យជ្រមុជទឹក ហើយដើម្បីពួកគេទទួលបាននូវបំណងប្រាថ្នាស្មោះស្មគ្រ័ នៅក្នុងការបន្តរក្សាព្រះបញ្ញត្តិរបស់ព្រះ បន្ទាប់ពីពួកគេត្រូវបានទទួលបុណ្យជ្រមុជទឹក និងដើម្បីពួកគេអាចត្រឡប់មកក្នុងវត្តមានរបស់ទ្រង់វិញ។ តើអ្នក ជាបងប្អូនប្រុសស្រីដ៏ល្អរបស់ខ្ញុំ ចង់ឱ្យក្រុមគ្រួសាររបស់អ្នក កូនចៅរបស់អ្នក ត្រូវបានផ្សាភ្ជាប់ទៅនឹងឪពុក និងម្តាយរបស់អ្នក ដែលគាត់បានលាចាកលោកទៅមុនអ្នកឬទេ? . . . បើសិនជាចង់ នោះអ្នកត្រូវតែចាប់ផ្តើមបង្រៀន ចាប់តាំងពីកូននៅយោលអង្រឹងទៅ។ អ្នកត្រូវបង្រៀនតាមរយៈការធ្វើជាគំរូ ក៏ដូចជាតាមរយៈសិក្ខាបទផងដែរ» (Conference Report ខែ តុលា ឆ្នាំ 1948 ទំព័រ 153)។

គំរូរបស់ម្តាយខ្ញុំ ក្នុងនាមជាគ្រូបង្រៀនក្នុងផ្ទះ អញ្ជើញឱ្យមាននូវគំនិតផ្សេងៗ និងកាន់តែទូលំទូលាយអំពីការបង្រៀន។ ពួកអ្នកដឹកនាំសាសនាចក្រ ចំណាយពេលដ៏ច្រើនលើសលប់គិតអំពីរបៀប ដើម្បីកែលំអការបង្រៀននៅក្នុងសាសនាចក្រ។ តើហេតុអ្វីបានជាយើងខំចំណាយពេល និងការខិតខំអស់ទាំងនេះ? នោះដោយសារតែយើងជឿទៅលើអំណាចដ៏មហិមានៃការបង្រៀន ដើម្បីបង្កើនសេចក្តីជំនឿរបស់បុគ្គលម្នាក់ៗ និងពង្រឹងដល់ក្រុមគ្រួសារ។ វាគឺជាជំនឿរបស់ខ្ញុំថា រឿងដ៏មានប្រសិទ្ធភាពបំផុតមួយ ដែលយើងអាចធ្វើ ដើម្បីកែលំអរការបង្រៀននៅក្នុងសាសនាចក្រ គឺត្រូវកែលំអការបង្រៀននៅក្នុងគេហដ្ឋានរបស់យើង។ ការបង្រៀនរបស់យើងនៅក្នុងផ្ទះ រៀបចំយើងឱ្យបង្រៀនកាន់តែមានប្រសិទ្ធភាពនៅក្នុងសាសនាចក្រ ហើយការបង្រៀននៅក្នុងសាសនាចក្រ ជួយយើងឱ្យបង្រៀនកាន់តែមានប្រសិទ្ធភាពនៅក្នុងផ្ទះ។ នៅទូទាំងសាសនាចក្រ មានតុជាច្រើននៅក្នុងបន្ទប់បាយ ដែលមានពេញទៅដោយឯកសារយោង និងសៀវភៅកំណត់ហេតុ ដែលមានពេញទៅដោយគំនិតយោបល់សម្រាប់បង្រៀនមេរៀន។ គ្មានអ្វីដែលថា ជាការរៀបចំជ្រុលហួសពេក ដើម្បីបង្រៀនដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនោះទេ ពីព្រោះការបំភ្លឺនៃដំណឹងល្អ អាចត្រូវបានបង្រៀននៅក្នុងផ្ទះជានិច្ច មិនថាជាវាត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀន ឬក៏អត់នោះទេ។

ឯកសារដ៏បំផុតគំនិត «ក្រុមគ្រួសារ៖ ការប្រកាសដល់ពិភពលោក» បានថ្លែងថា៖ «ប្តីប្រពន្ធមានភារៈកិច្ចដ៏ឧឡារិក ដើម្បីស្រឡាញ់ថែរក្សាគ្នាទៅវិញទៅមក ព្រមទាំងស្រឡាញ់ ថែរក្សាកូនចៅរបស់ខ្លួនឯងផង។ ‛កូនចៅជាមរតកមកពីព្រះយេហូវ៉ា» (ទំនុកដំកើង 127:3)។ ឪពុកម្តាយ មានកាតព្វកិច្ចពិសិដ្ឋ ក្នុងការថែ

រក្សាអប់រំកូនចៅរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងដោយសេចក្តីសុចរិត ដើម្បីចិញ្ចឹមកូនចៅខាងផ្លូវសាច់ឈាម និងផ្លូវវិញ្ញាណ តាមសេចក្តីត្រូវការរបស់ពួកគេ ដើម្បីបង្រៀនកូនចៅឱ្យចេះស្រឡាញ់គ្នា ហើយបំរើគ្នាទៅវិញទៅមក ចេះគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋគោរពច្បាប់ នៅទីកន្លែងណាក៏ដោយដែលគេរស់នៅ...។ តាមគម្រោងការរបស់ព្រះ ឪពុកបានចាត់ឱ្យធ្វើជាប្រធានដឹកនាំគ្រួសាររបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ហើយមានភារៈកិច្ចក្នុងការផ្តល់នូវសេចក្តីត្រូវការក្នុងជីវិត ព្រមទាំងការពារគ្រួសារខ្លួនផង។ ម្តាយមានភារៈកិច្ចទីមួយ ដើម្បីថែទាំបីបាច់កូនចៅរបស់ខ្លួន។ នៅក្នុងភារៈកិច្ចពិសិដ្ឋទាំងនេះ ឪពុកម្តាយមានភារៈកិច្ចឱ្យចេះជួយគ្នាទៅវិញទៅមកជាគូស្មើគ្នា»។

ស្របទៅតាម «ក្រុមគ្រួសារៈ ការប្រកាសដល់ពិភពលោក» គោលការណ៍ទាំងឡាយ ដែលខ្ញុំបានបង្រៀនអំពីការបង្រៀននៅក្នុងផ្ទះ អនុវត្តចំពោះឪពុក និងម្តាយ ប៉ុន្តែសំខាន់ចំពោះតួនាទីរបស់ម្តាយជាពិសេស។ ជារឿយៗ ឪពុកចំណាយពេលច្រើនបំផុត នៅកន្លែងការងាររបស់ពួកគេនៅក្រៅផ្ទះ។ នេះជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលការទទួលខុសត្រូវក្នុងការបង្រៀនដល់កូនៗនៅក្នុងផ្ទះ ធ្លាក់មកលើម្តាយ។ ខណៈដែលស្ថានភាពខុសៗគ្នា និងស្ថានភាពពិសេស ពុំតែងតែកើតមាន នោះខ្ញុំជឿថា តាមគម្រោងរបស់ព្រះថា តួនាទីនៃភាពជាម្តាយ គូសបញ្ជាក់អំពីការចិញ្ចឹមបីបាច់ និងការបង្រៀនដល់មនុស្សជំនាន់ក្រោយ។ យើងមើលឃើញមានឧបសគ្គយ៉ាងច្រើននៅសព្វថ្ងៃនេះ មកពីឥទ្ធិពលនៃការរំខាន និងការបំផ្លាញ ប៉ុនប៉ងមកនាំកូនចៅរបស់ព្រះដើរខុសផ្លូវ។ យើងមើលឃើញមនុស្សវ័យក្មេងជាច្រើន ដែលមិនសូវចាក់ឫសយ៉ាងមាំខាងវិញ្ញាណ ដើម្បីបន្តឈរនៅក្នុងសេចក្តីជំនឿ នៅពេលព្យុះភ្លៀងនៃការឥតជំនឿ និងអស់សង្ឃឹមបោកបក់មកលើពួកគេ។ មានកូនចៅរបស់ព្រះវរបិតាសួគ៌របស់យើងជាច្រើន ត្រូវបានបំណងប្រាថ្នាខាងលោកិយយកឈ្នះលើពួកគេ។ ការវាយប្រហារនៃអំពើទុច្ចរិតមកលើកូនចៅរបស់យើង គឺកាន់តែមានភាពប៉ិនប្រសប់ និងខ្លាំងក្លាជាងមុន។ ការបង្រៀនអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងគេហដ្ឋាន បន្ថែមនូវការការពារដល់កូនចៅរបស់យើងពីឥទ្ធិពលទាំងឡាយរបស់លោកិយ។

សូមឱ្យព្រះប្រទានពរដល់អ្នក ដែលជាម្តាយ និងឪពុកនៅក្នុងស៊ីយ៉ូនដ៏អស្ចារ្យ។ ទ្រង់បានផ្តល់សិទ្ធិឱ្យអ្នកមើលថែ ដល់កូនចៅដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ក្នុងនាមជាឪពុកម្តាយ យើងចាប់ដៃគ្នា ព្រមជាមួយនឹងការចូលរួមជាមួយព្រះ នៅក្នុងការនាំមកនូវកិច្ចការ និងសិរីល្អរបស់ទ្រង់ ក្នុងចំណោមកូនចៅរបស់ទ្រង់។ វាគឺជាកាតព្វកិច្ចដ៏ពិសិដ្ឋរបស់យើង ដើម្បីខិតខំដោយអស់ពីសមត្ថភាពរបស់យើង។ ខ្ញុំធ្វើសក្ខីភាពអំពីការនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។